ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

តុលាការរដ្ឋប្បវេណី

**សំណុំរឿងរដ្ឋប្បវេណីលេខ ៦៥២**

ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១

**សាលក្រមរដ្ឋប្បវេណីលេខ ០០៧ ឋ**

ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្ដាល

កាលបរិច្ឆេទនៃការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ៖ ថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២។

កាលបរិច្ឆេទនៃការប្រកាសសាលក្រម ៖ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២។

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល និងជាចៅក្រមជំនុំជម្រះ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**ក. អំពីអត្តសញ្ញាណភាគី**

**ដើមចោទ**

ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៥៧ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

អត្តសញ្ញាណសញ្ជាតិខ្មែរលេខ ០២០០១០៧៩៨ (០១)។

អាសយដ្ឋានផ្ទះលេខA1B1 ផ្លូវ២១B ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល។

**អ្នកតំណាងដោយអាណត្តិ៖**

លោក [redacted] អត្តលេខ ៦៦៨ ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

លោក [redacted] អត្តលេខ ៩៨២ ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

កញ្ញា [redacted] អត្តលេខ ២៣៦៩T ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យ៖ [redacted] អគារលេខ [redacted]។

**សហចុងចម្លើយ៖**

១. ឈ្មោះ [redacted] ភេទប្រុស អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៨៧៤៨៣៦។

២. ឈ្មោះ [redacted] ភេទស្រី អត្តសញ្ញាណប័ណ្ណលេខ ០១០៨៧៤៨៣៦។



Scanned with CamScanner

អាសយដ្ឋានផ្ទះលេខ ៣៨ច ផ្លូវសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់សែនសុខ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិរបស់សហចុងចម្លើយ៖**

លោក [redacted] អត្តលេខ ១៩៧៩ ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យ៖ [redacted] អគារលេខ ៣៦ បន្ទប់ P១០-១១ ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

## អង្គហេតុ និងចំណុចវិវាទ

### ក. ខ្លឹមសារនៃពាក្យបណ្តឹងដែលដើមចោទទាមទារឱ្យតុលាការចេញ

១. បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] ម៉េងហួត៖

ក. សងប្រាក់ចំនួន ៦៦.០០០ (ប្រាំមួយម៉ឺនប្រាំមួយពាន់) ដុល្លារអាមេរិក។

ខ. សងការប្រាក់ដើមគ្រាចំនួន ១០.៦២៦ (មួយម៉ឺនប្រាំមួយពាន់ម្ភៃប្រាំមួយ) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃ២១ ខែធ្នូ ឆ្នាំ២០២០ បូករួមនឹងការប្រាក់ប្រចាំខែស្មើនឹង ២.៥ (ពីរក្បៀសប្រាំ) ភាគរយក្នុងមួយខែនៃប្រាក់ដើមដែលនៅសល់គិតចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ រហូតដល់កាលបរិច្ឆេទដែលសហចុងចម្លើយទូទាត់ប្រាក់ដើម និងការប្រាក់គ្រប់ចំនួន។

គ. បង់ការប្រាក់ពិន័យ ១,៥ (មួយក្បៀសប្រាំ) ភាគរយ ក្នុងមួយខែ នៃប្រាក់ដើមស្របតាមតារាងកាលវិភាគបង់ប្រាក់ដោយគិតចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ រហូតដល់កាលបរិច្ឆេទដែលសហចុងចម្លើយទូទាត់ប្រាក់ដើម និងការប្រាក់គ្រប់ចំនួន។

ឃ. សងសំណងខូចខាតពេលវេលាចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក

ង. សេវាកម្មច្បាប់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ឱ្យទៅដើមចោទ ឈ្មោះ ជាម ឈិត។

២. សាលក្រមនេះអាចប្រកាសអនុវត្តបណ្តោះអាសន្នបាន។

### ខ. ដំណើររឿងក្តី និងចំណុចវិវាទ

#### ខ.១. ការសង្ខេបអំពីរឿងក្តី

ថ្ងៃទី២៩ ខែ មិថុនា ឆ្នាំ២០២០ ដើមចោទបានចុះកិច្ចសន្យាខ្ចីប្រាក់-ដាក់បញ្ចាំជាមួយចុងចម្លើយ ទឹកប្រាក់ចំនួន ៨៥.០០០ (ប្រាំបីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក និងព្រមព្រៀងបង្កើតការប្រាក់ចំនួន ២,៥ ភាគរយ នៃប្រាក់ដើមក្នុងមួយខែស្មើនឹង ២.១២៥ (ពីរពាន់មួយរយម្ភៃប្រាំ) ដុល្លារអាមេរិក ដែលមានរយៈពេលនៃការខ្ចីចំនួន ០៣ ខែ គិតចាប់ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០។ ចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា ដោយមិនបានបង់ការប្រាក់ និងប្រាក់ដើមឱ្យមកដើមចោទ។

ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ ដើមចោទ និងចុងចម្លើយបានចុះកិច្ចព្រមព្រៀងស្តីពីការសងប្រាក់ ដោយចុងចម្លើយយល់ព្រមសងប្រាក់ជូនដើមចោទនៃប្រាក់ដែលជំពាក់ចំនួន ៨៥.០០០ (ប្រាំបីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក និងការប្រាក់ដើមគ្រាសរុបចំនួន ១០.៦២៥ (មួយម៉ឺនប្រាំមួយរយម្ភៃប្រាំ) ដុល្លារអាមេរិក ជាដំណាក់កាល១ ដូចមានចែងក្នុងប្រការ ១ នៃកិច្ចព្រមព្រៀង។



Scanned with CamScanner

បន្ទាប់ពីចុះកិច្ចព្រមព្រៀងរួច ចុងចម្លើយបានសងរំលោះប្រាក់ដើមបានចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ ដោយសុំមិនទាន់បង់ការប្រាក់ គឺនឹងសងការប្រាក់នៅខែបន្តបន្ទាប់។ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ ជាថ្ងៃដែលចុងចម្លើយត្រូវបង់រំលោះប្រាក់ដើមជាលើកទី២ ស្មើនឹង ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ជាមួយនឹងការប្រាក់ត្រូវបង់ប្រចាំខែស្មើនឹង ២,៥ % ដែលការប្រាក់នេះ គិតចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ រហូតដល់ថ្ងៃសងរំលោះប្រាក់ដើមជាលើកទី២ ស្មើនឹង ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ តែចុងចម្លើយមិនបានសងប្រាក់តាមការកំណត់។ ថ្ងៃទី០២ ខែមេសា ឆ្នាំ២០២១ ដើមចោទបានធ្វើលិខិតដាស់តឿនឱ្យចុងចម្លើយបង់ប្រាក់តាមតារាងកាលវិភាគបង់ប្រាក់។ ក្រោយពីបានទទួលលិខិតជូនដំណឹង ចុងចម្លើយបានសុំសងប្រាក់ដើមជូនដើមចោទជាបន្តបន្ទាប់បានចំនួន ៩,០០០ (ប្រាំបួនពាន់) ដុល្លារអាមេរិក ដោយប្រាក់ដែលនៅសល់ចំនួន ១,០០០ (មួយពាន់) ដុល្លារអាមេរិកទៀត នឹងសងបង្គប់នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ ចំណែកការប្រាក់ដែលនៅសល់ក៏ចុងចម្លើយសុំសងនៅខែបន្តបន្ទាប់ជាមួយនឹងការប្រាក់ពីមុនៗផងដែល។ ដល់ថ្ងៃកំណត់ត្រូវសងប្រាក់លើកទី៣ ស្មើនឹង ២៥.០០០ (ពីរម៉ឺនប្រាំពាន់) ដុល្លារអាមេរិក បូកនឹងប្រាក់ដែលនៅជំពាក់ចំនួន ១,០០០ (មួយពាន់) ដុល្លារអាមេរិក តែចុងចម្លើយមិនសងប្រាក់ និងការប្រាក់តាមការសន្យានោះឡើយ រហូតមកដល់បច្ចុប្បន្ន។

**១.២. អង្គហេតុដែលគ្មានវិវាទ៖ គ្មាន។**

**១.៣. អំពីចំណុចវិវាទ**

**១.៣.១. ស្តីពីចំណុចវិវាទទី១៖**

"តើការទាមទារឱ្យសហចុងចម្លើយសងប្រាក់ចំនួន ៦៦.០០០ (ប្រាំមួយម៉ឺនប្រាំមួយពាន់) ដុល្លារអាមេរិក ដោយផ្អែកលើកិច្ចព្រមព្រៀងស្តីពីការសងប្រាក់ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ ជាការត្រឹមត្រូវទេ?"

**១.៣.២. ស្តីពីចំណុចវិវាទទី២៖**

"តើការទាមទារឱ្យសហចុងចម្លើយសងការប្រាក់ដើមគ្រាចំនួន ១០.៦២៦ (មួយម៉ឺនប្រាំមួយពាន់ម្ភៃប្រាំមួយ) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ បូករួមនឹងការប្រាក់ប្រចាំខែស្មើនឹង ២,៥ (ពីរក្បៀសប្រាំ) ភាគរយ ក្នុងមួយខែ នៃប្រាក់ដើម ដែលនៅសល់គិតចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ រហូតដល់កាលបរិច្ឆេទដែលសហចុងចម្លើយទូទាត់ប្រាក់ដើម និងការប្រាក់គ្រប់ចំនួនដែរទេ?"

**១.៣.៣. ស្តីពីចំណុចវិវាទទី៣៖**

"តើការទាមទារឱ្យសហចុងចម្លើយសងការប្រាក់ពិន័យ ១,៥ (មួយក្បៀសប្រាំ ភាគរយ នៃប្រាក់ដើមស្របតាមតាងកាលវិភាគបង់ប្រាក់ដោយគិតចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ រហូតដល់កាលបរិច្ឆេទដែលសហចុងចម្លើយទូទាត់ប្រាក់ដើម និងការប្រាក់គ្រប់ចំនួន ត្រឹមត្រូវដែរទេ?"

**១.៤. ការអះអាងរបស់ភាគី**

**១.៤.១. ស្តីពីចំណុចវិវាទទី១ ទី២ ទី៣, ការទាមទារក្នុងចំណុចទី១ (ឃ.ង) និងទី២ នៃពាក្យបណ្តឹង**

**ក. ការអះអាងរបស់ដើមចោទ៖** នាងខ្ញុំជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ សូមរក្សាខ្លឹមសារនៃពាក្យបណ្តឹងចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១ និងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុ

ផលចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ ទុកជាបានការដដែល ដោយក្នុងនោះកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ ដើមចោទបានចុះកិច្ចសន្យាខ្ចីប្រាក់-ដាក់បញ្ចាំ ជាមួយចុងចម្លើយ។ ក្នុងកិច្ចសន្យាខ្ចីប្រាក់-ដាក់បញ្ចាំ ចុងចម្លើយបានខ្ចីប្រាក់ពីដើមចោទចំនួន ៨៥.០០០ (ប្រាំបីម៉ឺនប្រាំពាន់ដុល្លារអាមេរិក) និងយល់ព្រមបង់ការប្រាក់ក្នុងអត្រា ២,៥ ភាគរយនៃប្រាក់ដើម ក្នុងមួយខែស្មើនឹង ២.១២៥ (ពីរពាន់មួយរយម្ភៃប្រាំដុល្លារអាមេរិក) ហើយរយៈពេលនៃការខ្ចីគឺ ០៣ ខែ គិតចាប់ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០។ គិតចាប់ពីពេលដែលចុងចម្លើយបានចុះកិច្ចព្រមព្រៀងរហូតដល់បច្ចុប្បន្ន ចុងចម្លើយមិនដែលបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចសន្យាម្តងណាឡើយ ពោល គឺមិនដែលបានបង់ការប្រាក់ និងប្រាក់ដើមឱ្យមកដើមចោទឡើយ ទោះបីជាដើមចោទ រួមជាមួយមេធាវីតំណាងដោយអាណត្តិធ្វើការដាស់តឿនទៅចុងចម្លើយឱ្យមកបង់ប្រាក់ជូនដើមចោទយ៉ាងណាក៏ដោយ។ ក្រោយមកដោយមានការស្នើសុំសងប្រាក់ពីចុងចម្លើយ និងដើមចោទ មានការយោគយល់អនុគ្រោះផងនោះ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ ដើមចោទ និងចុងម្លើយបានចុះកិច្ចព្រមព្រៀងស្តីពីការសងប្រាក់ដែលខ្លឹមសារនៃកិច្ចព្រមព្រៀងនោះ គឺចុងម្លើយយល់ព្រមសងប្រាក់ជូនដើមចោទ នៃប្រាក់ដែលបានជំពាក់ចំនួន ៨៥,០០០ (ប្រាំបីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក និងការប្រាក់ដើមគ្រាសរុបចំនួន ១០.៦២៥ (មួយម៉ឺនប្រាំមួយរយម្ភៃប្រាំ) ដុល្លារអាមេរិក ជាដំណាក់កាលៗ ដូចមានចែងក្នុងប្រការ ១ នៃកិច្ចព្រមព្រៀង។ បន្ទាប់ពីចុះកិច្ចព្រមព្រៀងស្តីពីការសងមក ចុងចម្លើយបានធ្វើការសង់រំលោះប្រាក់ដើមបានចំនួន ១០.០០០ (មួយម៉ឺនដុល្លារអាមេរិក) នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ ដោយសុំមិនទាន់បង់ការប្រាក់ឡើយ គឺនឹងសងការប្រាក់នៅខែបន្តបន្ទាប់។ រហូតដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ ជាថ្ងៃដែលចុងចម្លើយ ត្រូវបង់រំលោះប្រាក់ដើមជាលើកទី២ ស្មើនឹង ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ជាមួយនឹងអាត្រាការប្រាក់ដែលត្រូវបង់ប្រចាំខែស្មើនឹង ២,៥% ដែលអាត្រាការ ប្រាក់នេះ គឺគិតគណនាចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ រហូតដល់ថ្ងៃសងរំលោះប្រាក់ដើមជាលើកទី២ ស្មើនឹង១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ តែចុងចម្លើយមិនបានសង់ប្រាក់តាមការកំណត់ឡើយ ទើបនៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០២១ ភាគីដើមចោទ តាមរយៈមេធាវីតំណាងដោយអាណត្តិបានធ្វើលិខិតដាស់តឿនឱ្យចុងចម្លើយ បង់ប្រាក់តាមតារាងកាលវិភាគបង់ប្រាក់។ ក្រោយពីចុងចម្លើយបានទទួលលិខិតជូនដំណឹងមក ចុងចម្លើយបានសុំសងប្រាក់ដើមជូនដើមចោទជាបន្តបន្ទាប់បានចំនួន ៩.០០០ (ប្រាំបួនពាន់) ដុល្លារអាមេរិក ដោយប្រាក់ដែលនៅសល់ចំនួន ១,០០០ (មួយពាន់) ដុល្លារអាមេរិកទៀត នឹងសងបង្គ្រប់នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ ចំណែកការប្រាក់ដែលនៅសល់ក៏ចុងចម្លើយសុំសងនៅខែបន្តបន្ទាប់ជាមួយ និងការប្រាក់ពីមុនៗផងដែល។ រហូតមកដល់ថ្ងៃកំណត់ត្រូវសងប្រាក់លើកទី៣ ស្មើនឹង ២៥.០០០ (ពីរម៉ឺនប្រាំពាន់) ដុល្លារអាមេរិក បូករួមនឹងប្រាក់ដែល នៅជំពាក់ចំនួន ១០០០ (មួយពាន់) ដុល្លារអាមេរិក តែចុងចម្លើយមិនសងប្រាក់ និងការប្រាក់តាមការសន្យានោះឡើយ។

**ខ. ការអះអាងរបស់សហចុងចម្លើយ៖** ដោយសារកន្លងមកពុំមានវត្តមានកូនក្តីខ្ញុំបាទ ដូច្នេះខ្ញុំបាទសូមទទួលស្គាល់ និងមិនទទួលស្គាល់លើការទាមទាររួមមាន ទទួលស្គាល់សងប្រាក់ចំនួន ៦៦.០០០ (ប្រាំមួយម៉ឺនប្រាំមួយពាន់) ដុល្លារអាមេរិក, បដិសេធការទាមទារការប្រាក់ដើមគ្រាចំនួន ១០.៦២៦ (មួយម៉ឺនប្រាំមួយពាន់ម្ភៃប្រាំមួយ) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ និងការប្រាក់ប្រចាំខែស្មើនឹង ២,៥ (ពីរក្បៀសប្រាំ)

ភាគរយ ក្នុង ០១ ខែ នៃប្រាក់ដើមដែលនៅសល់គិតចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០, បដិសេធការទាមទារការបង់ការប្រាក់ពិន័យ ១,៥ (មួយក្បៀសប្រាំ) ភាគរយ នៃប្រាក់ដើមស្របតាមតារាងកាលវិភាគបង់ប្រាក់ដោយគិតចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ រហូតដល់កាលបរិច្ឆេទដែលសហចុងចម្លើយទូទាត់ប្រាក់ដើម និងការប្រាក់គ្រប់ចំនួន, បដិសេធសំណងការខូចខាតពេលវេលា និងសេវាផ្លូវច្បាប់របស់ដើមចោទ និងបដិសេធដោយពុំមានការចាំបាច់ក្នុងការទាមទារអនុវត្តបណ្ដោះអាសន្ននោះទេ។

**សំអាងហេតុ**

**ក. ស្ដីពីចំណុចវិវាទទី១៖** ការទាមទារឱ្យសហចុងចម្លើយសងប្រាក់ចំនួន ៦៦.០០០ (ប្រាំមួយម៉ឺនប្រាំមួយពាន់) ដុល្លារអាមេរិក ដោយផ្អែកលើកិច្ចព្រមព្រៀងស្ដីពីការសងប្រាក់ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០

**ក.១. ការទទួលស្គាល់អង្គហេតុ**

តាមសេចក្ដីថ្លែងការណ៍របស់សហចុងចម្លើយចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ បានទទួលស្គាល់នូវការទាមទាររបស់ដើមចោទនូវប្រាក់ចំនួន ៦៦.០០០ (ប្រាំមួយម៉ឺនប្រាំមួយពាន់) ដុល្លារអាមេរិក។ ក្នុងកំណត់ហេតុស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់ អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយបានទទួលស្គាល់នូវសេចក្ដីថ្លែងការណ៍របស់សហចុងចម្លើយចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២។ តុលាការយល់ឃើញថា ចុងចម្លើយបានទទួលការទាមទាររបស់ដើមចោទនូវប្រាក់ចំនួន ៦៦.០០០ (ប្រាំមួយម៉ឺនប្រាំមួយពាន់) ដុល្លារអាមេរិក។ តាមមាត្រា ១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការពុំចាំបាច់ធ្វើការទទួលស្គាល់អង្គហេតុនៃការបង្កើតកិច្ចសន្យាខ្ចីប្រាក់ដោយភស្ដុតាងនោះទេ ព្រោះសហចុងចម្លើយបានសារភាពអំពីអង្គហេតុរួចហើយ។

**ក.២. ការវិនិច្ឆ័យ**

***ដោយសហចុងចម្លើយបានទទួលស្គាល់នូវការទាមទាររបស់ដើមចោទនូវប្រាក់ចំនួន ៦៦.០០០ (ប្រាំមួយម៉ឺនប្រាំមួយពាន់) ដុល្លារអាមេរិក តុលាការនឹងសម្រេចឱ្យសហចុងចម្លើយសងប្រាក់ចំនួន ៦៦.០០០ (ប្រាំមួយម៉ឺនប្រាំមួយពាន់) ដុល្លារអាមេរិកឱ្យដើមចោទ។***

**ខ. ស្ដីពីចំណុចវិវាទទី២៖** ការទាមទារឱ្យសហចុងចម្លើយសងការប្រាក់ដើមគ្រាចំនួន ១០.៦២៦ (មួយម៉ឺនប្រាំមួយពាន់ម្ភៃប្រាំមួយ) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ រហូតដល់ថ្ងៃសងគ្រប់

**ខ.១. ការទទួលស្គាល់អង្គហេតុ**

ចុងចម្លើយទទួលស្គាល់ថា ពិតជាបានបង្កើតកិច្ចសន្យាខ្ចីប្រាក់-ដាក់បញ្ចាំចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ រវាងដើមចោទ និងចុងចម្លើយ មានកម្មវត្ថុនៃកិច្ចសន្យាខ្ចីបរិភោគជាទឹកប្រាក់ចំនួន ៨៥.០០០ (ប្រាំបីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក និងការប្រាក់ចំនួន ២,៥ ភាគរយនៃប្រាក់ចំនួន ៨៥.០០០ (ប្រាំបីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ក្នុងមួយខែស្មើនឹង ២.១២៥ (ពីរពាន់មួយរយម្ភៃប្រាំ) ដុល្លារអាមេរិក មានរយៈពេលនៃការខ្ចីចំនួន ០៣ ខែ គិតចាប់ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០។ ប៉ុន្តែចុងចម្លើយបានតវ៉ាចំពោះអត្រាការប្រាក់ថា មានចំនួនលើសពីអត្រាការប្រាក់ដែលបានកម្រិត ទោះបីជាមានការព្រមព្រៀងគ្នាក៏ដោយ។

**ខ.២. ការវិនិច្ឆ័យ**

ដើមចោទ និងចុងចម្លើយបានបង្កើតកិច្ចសន្យាខ្ចីប្រាក់-ដាក់បញ្ចាំចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ មានកម្មវត្ថុនៃកិច្ចសន្យាខ្ចីបរិភោគជាទឹកប្រាក់ចំនួន ៨៥.០០០ (ប្រាំបីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក និងការប្រាក់ចំនួន ២,៥ ភាគរយនៃប្រាក់ចំនួន ៨៥.០០០ (ប្រាំបីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ក្នុងមួយខែស្មើនឹង ២.១២៥ (ពីរពាន់មួយរយម្ភៃប្រាំ) ដុល្លារអាមេរិក មានរយៈពេលនៃការខ្ចីចំនួន ០៣ ខែ គិតចាប់ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០។ ដើមចោទទាមទារឱ្យចុងចម្លើយសងការប្រាក់ចំនួន ១០.៦២៦ (មួយម៉ឺនប្រាំមួយពាន់ម្ភៃប្រាំមួយ) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃ២១ ខែធ្នូ ឆ្នាំ២០២០ រហូតដល់កាលបរិច្ឆេទដែលសហចុងចម្លើយទូរទាត់ប្រាក់ដើម និងការប្រាក់គ្រប់ចំនួន ព្រោះកិច្ចសន្យាត្រូវបានបង្កើតឡើងនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ និងបញ្ចប់នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ ដោយចុងចម្លើយត្រូវបង់ការប្រាក់ចំនួន ២.៥ ភាគរយក្នុងមួយខែ ស្មើនឹងចំនួន ២,១២៥ (ពីរពាន់មួយរយម្ភៃប្រាំ) ដុល្លាអាមេរិកក្នុងមួយខែ។ ប៉ុន្តែបើគណនាការប្រាក់ចំនួន ១០.៦២៦ (មួយម៉ឺនប្រាំមួយពាន់ម្ភៃប្រាំមួយ) ដុល្លារអាមេរិកនៃតម្លៃការប្រាក់ក្នុងមួយខែវិញ ឃើញថា ការប្រាក់ចំនួន ១០.៦២៦ (មួយម៉ឺនប្រាំមួយពាន់ម្ភៃប្រាំមួយ) ដុល្លារអាមេរិក ស្មើនឹងការប្រាក់ចំនួន ០៥ (ប្រាំ) ខែ គិតចាប់ពីថ្ងៃ២១ ខែមិថុនា ឆ្នាំ២០២០ ដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០។ កិច្ចសន្យានេះ មានអត្រាការប្រាក់ស្មើនឹងចំនួន ៣០ (សាមសិប) ភាគរយ បើគិតជាអត្រាការប្រាក់ក្នុងមួយឆ្នាំ នាំឱ្យអត្រាការប្រាក់ដែលភាគីបានព្រមព្រៀងនេះមានចំនួនលើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិតគឺ ចំនួន ១៨ ភាគរយក្នុងមួយឆ្នាំ ឬស្មើនឹង ១.៥ (មួយក្បៀសប្រាំ) ភាគរយក្នុងមួយខែ ហេតុនេះ តាមមាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី កិច្ចសន្យាខ្ចីប្រាក់-ដាក់បញ្ចាំចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ ត្រូវទុកជាមោឃៈលើភាគដែលលើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិត។ ដោយរយៈពេលនៃការខ្ចីចំនួន ០៣ ខែ គិតចាប់ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ ហេតុនេះ ការទាមទារឱ្យចុងចម្លើយសងប្រាក់ដែលលើសចំនួន ០២ (ពីរ) ខែទៀត គឺជាការមិនត្រឹមត្រូវ ព្រោះតាមមាត្រា ៥៩៤ នៃក្រមរដ្ឋប្បវេណី លុះត្រាតែដល់ពេលកំណត់សងទើបអ្នកឱ្យខ្ចីអាចធ្វើការទាមទារឱ្យអ្នកខ្ចីសងមកខ្លួនវិញបាន នាំឱ្យអង្គហេតុចម្បងក្នុងការទាមទារឱ្យចុងចម្លើយធ្វើការសងការប្រាក់ចំនួន ១.៥ (មួយក្បៀសប្រាំ) ភាគរយក្នុងមួយខែ កើតឡើងនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ ហើយចុងចម្លើយដល់កំណត់សងនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៩។ តុលាការនឹងសម្រេចឱ្យចុងចម្លើយសងការប្រាក់ឱ្យស្របទៅនឹងអត្រាការប្រាក់ដែលបានកម្រិត និងក្នុងរយៈពេលនៃកម្ចីដែលមានរយៈពេលចំនួន ០៣ (បី) ខែ ហេតុនេះ ***ការប្រាក់ចំនួន ១.៥ ភាគរយក្នុងមួយខែនៃប្រាក់ចំនួន ៨៥.០០០ (ប្រាំបីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ស្មើនឹងចំនួន ១,២៧៥ (មួយពាន់ពីររយចិតសិបប្រាំ) ដុល្លារអាមេរិក ក្នុងមួយខែ ឬស្មើនឹងចំនួន ៣,៨២៥ (បីពាន់ប្រាំបីរយម្ភៃប្រាំ) ដុល្លារអាមេរិក ក្នុងរយៈពេល ០៣ ខែ ចាប់ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០។***

**គ. ស្តីពីចំណុចវិវាទទី២៖** “តើការទាមទារឱ្យសហចុងចម្លើយសងការប្រាក់ប្រចាំខែស្មើនឹង ២,៥ (ពីរក្បៀសប្រាំ) ភាគរយ ក្នុងមួយខែ នៃប្រាក់ដើមដែលនៅសល់គិតចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ រហូតដល់កាលបរិច្ឆេទដែលសហចុងចម្លើយទូទាត់ប្រាក់ដើម និងការប្រាក់គ្រប់ចំនួនដែរទេ?”

**គ.១. ការទទួលស្គាល់អង្គហេតុ**



Scanned with CamScanner

ដើមចោទ និងចុងចម្លើយបានទទួលស្គាល់ថា បានបង្កើតកិច្ចព្រមព្រៀងចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ លើប្រាក់ចំនួន ៨៥.០០០ (ប្រាំបីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក លើអត្រាការប្រាក់ចំនួន ២.៥ (ពីរក្បៀសប្រាំ) ភាគរយក្នុងមួយខែ ចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ និងបានបង្កើតរបៀបនៃការសងប្រាក់ដូចមានក្នុងកិច្ចព្រមព្រៀង ដោយក្នុងនោះចុងចម្លើយត្រូវ៖

| ចំនួនខែ | ប្រាក់ដើម គិតជាដុល្លារអាមេរិក | អត្រាការប្រាក់ គិតជាភាគរយ | អត្រាការប្រាក់ ប្រចាំខែ | ចំនួនប្រាក់ដើម ខែត្រូវសង | កាលបរិច្ឆេទនៃ ការសង |
|---|---|---|---|---|---|
| ខែទី១ | ៨៥.០០០ | ២.៥% | ២១២៥ | ១០.០០០ | ២១.១២.២០២០ |
| ខែទី២ | ៧៥.០០០ | ២.៥% | ១៨៧៥ | ០ | |
| ខែទី៣ | ៧៥.០០០ | ២.៥% | ១៨៧៥ | ០ | |
| ខែទី៤ | ៧៥.០០០ | ២.៥% | ១៨៧៥ | ១០.០០០ | ៣០.០៣.២០២១ |
| ខែទី៥ | ៦៥.០០០ | ២.៥% | ១៦២៥ | ០ | |
| ខែទី៦ | ៦៥.០០០ | ២.៥% | ១៦២៥ | ០ | |
| ខែទី៧ | ៦៥.០០០ | ២.៥% | ១៦២៥ | ០ | |
| ខែទី៨ | ៦៥.០០០ | ២.៥% | ១៦២៥ | ២៥.០០០ | ៣០.០៧.២០២១ |
| ខែទី៩ | ៤០.០០០ | ២.៥% | ១០០០ | ០ | |
| ខែទី១០ | ៤០.០០០ | ២.៥% | ១០០០ | ០ | |
| ខែទី១១ | ៤០.០០០ | ២.៥% | ១០០០ | ២០.០០០ | ៣០.១០.២០២១ |
| ខែទី១២ | ២០.០០០ | ២.៥% | ៥០០ | ០ | |
| ខែទី១៣ | ២០.០០០ | ២.៥% | ៥០០ | ២០.០០០ | ៣០.១២.២០២១ |

ដើមចោទ និងចុងចម្លើយទទួលស្គាល់ថា ចុងចម្លើយបានសងប្រាក់ជាបន្តបន្ទាប់បានចំនួន ១៩.០០០ (មួយម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក ហើយពុំបានសងការប្រាក់នោះទេ ហេតុនេះ ចុងចម្លើយនៅជំពាក់ប្រាក់ដើមរបស់ដើមចោទនៅចំនួន ៦៦.០០០ (ប្រាំមួយម៉ឺនប្រាំមួយពាន់) ដុល្លារអាមេរិក និងការប្រាក់។

តុលាការទទួលស្គាល់អង្គហេតុនៃការបង្កើតការប្រាក់ជាលាយលក្ខណ៍អក្សរលើការប្រាក់ចំនួន ២.៥ (ពីរក្បៀសប្រាំ) ភាគរយ ក្នុងមួយខែ តាមកិច្ចព្រមព្រៀងចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ តាមមាត្រា ៥៨៣ នៃក្រមរដ្ឋប្បវេណី។

### គ.២. ការវិនិច្ឆ័យ

ដើមចោទ និងចុងចម្លើយបានបង្កើតកិច្ចសន្យាចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ មានកម្មវត្ថុនៃកិច្ចសន្យាខ្ចីបរិភោគជាទឹកប្រាក់ចំនួន ៨៥.០០០ (ប្រាំបីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក និងការប្រាក់ចំនួន ២,៥ ភាគរយនៃប្រាក់ចំនួន ៨៥.០០០ (ប្រាំបីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ក្នុងមួយខែស្មើនឹង ២.១២៥ (ពីរពាន់មួយរយម្ភៃប្រាំ) ដុល្លារអាមេរិក ដោយបានកំណត់អំពីរបៀបនៃការសងប្រាក់ និងការប្រាក់ មានរយៈពេលនៃការខ្ចីគិតចាប់ពីថ្ងៃ



Scanned with CamScanner

ទី២១ ខែធ្នូ ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ដូចមានក្នុងតារាងខាងលើនេះ។ ដើមចោទទាមទារឱ្យចុងចម្លើយសងការប្រាក់ចំនួន ២.៥ (ពីរក្បៀសប្រាំ) ភាគរយ គិតចាប់ពីថ្ងៃ២១ ខែធ្នូ ឆ្នាំ២០២០ រហូតដល់កាលបរិច្ឆេទដែលសហចុងចម្លើយទូរទាត់ប្រាក់ដើម និងការប្រាក់គ្រប់ចំនួន ព្រោះកិច្ចសន្យាត្រូវបានបង្កើតឡើងនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ និងបញ្ចប់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ដោយចុងចម្លើយត្រូវបង់ប្រាក់ដើមតាមការព្រៀង និងបង់ការប្រាក់ចំនួន ២.៥ ភាគរយក្នុងមួយខែនៃប្រាក់ដើមដែលនៅសល់។ តាមភស្តុតាងបង្ហាញថា ចុងចម្លើយពុំបានសងប្រាក់ដើមតាមការកំណត់ដូចមានក្នុងកិច្ចសន្យានោះទេ តែដើមចោទនបានទទួលការបង់ប្រាក់ដើមរបស់ចុងចម្លើយ ចំណែកការប្រាក់ប្រចាំខែ ចុងចម្លើយមិនបានបង់នោះទេ។ តុលាការយល់ឃើញថា កិច្ចសន្យានេះ មានអត្រាការប្រាក់ស្មើនឹងចំនួន ៣០ (សាមសិប) ភាគរយ បើគិតជាអត្រាការប្រាក់ក្នុងមួយឆ្នាំ នាំឱ្យអត្រាការប្រាក់ដែលភាគីបានព្រមព្រៀងនេះមានចំនួនលើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិតគឺ ចំនួន ១៨ ភាគរយក្នុងមួយឆ្នាំ ឬស្មើនឹង ១.៥ (មួយក្បៀសប្រាំ) ភាគរយក្នុងមួយខែ ហេតុនេះ តាមមាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី កិច្ចសន្យាខាងលើត្រូវទុកជាមោឃៈលើភាគដែលលើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិត។ ដោយរយៈពេលនៃការខ្ចីគិតចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ប៉ុន្តែចុងចម្លើយឈប់បង់ប្រាក់ដើមឱ្យដើមចោទលើកទី៣ និងត្រូវបានដើមចោទដាក់ពាក្យបណ្តឹងទាមទារប្រាក់នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១។ ហេតុនេះ ការទាមទារឱ្យចុងចម្លើយសងប្រាក់គិតចាប់ពីថ្ងៃ២១ ខែធ្នូ ឆ្នាំ២០២០ រហូតដល់កាលបរិច្ឆេទដែលសហចុងចម្លើយទូរទាត់ប្រាក់ដើម និងការប្រាក់គ្រប់ចំនួន គឺជាការមិនត្រឹមត្រូវ ព្រោះតាមមាត្រា ៥៩៤ នៃក្រមរដ្ឋប្បវេណី លុះត្រាតែដល់ពេលកំណត់សងទើបអ្នកឱ្យខ្ចីអាចធ្វើការទាមទារឱ្យអ្នកខ្ចីសងមកខ្លួនវិញបាន ហើយដើមចោទបានសម្តែងឆន្ទៈរំលាយកិច្ចសន្យានៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១ ដែលជាថ្ងៃដាក់ពាក្យបណ្តឹង នាំឱ្យអង្គហេតុចម្បងក្នុងការទាមទារឱ្យចុងចម្លើយធ្វើការសងការប្រាក់ដើមកើតឡើងនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២១ លើប្រាក់ចំនួន ៦៦.០០០ (ប្រាំមួយម៉ឺនប្រាំមួយពាន់) ដុល្លារអាមេរិក និងការប្រាក់ដូចមានក្នុងតារាងខាងក្រោម ចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១ ជាថ្ងៃដែលកិច្ចសន្យាត្រូវបានរំលាយ។

តារាងខាងក្រោមនេះ គឺជាតារាងនៃការសងប្រាក់ជាក់ស្តែងរវាងដើមចោទ និងចុងចម្លើយ៖

| ចំនួនខែ | ប្រាក់ដើម គិតជាដុល្លារអាមេរិក | អត្រាការប្រាក់ គិតជាភាគរយ | អត្រាការប្រាក់ ប្រចាំខែ | ចំនួនប្រាក់ដើម ខែត្រូវសង | កាលបរិច្ឆេទនៃ ការសង |
|---|---|---|---|---|---|
| ខែទី១ | ៨៥.០០០ | ១.៥% | ១២៧៥ | ១០.០០០ | ២១.១២.២០២០ |
| ខែទី២ | ៧៥.០០០ | ១.៥% | ១១២៥ | ០ | |
| ខែទី៣ | ៧៥.០០០ | ១.៥% | ១១២៥ | ០ | |
| ខែទី៤ | ៧៥.០០០ | ១.៥% | ១១២៥ | ១០.០០០ | ៣០.០៣.២០២១ |
| ខែទី៥ | ៧៥.០០០ | ១.៥% | ១១២៥ | ២០០០ | ១៣.០៤.២០២១ |
| ខែទី៦ | ៧៣.០០០ | ១.៥% | ១០៩៥ | ២០០០ | ២៥.០៤.២០២១ |
| ខែទី៧ | ៧១.០០០ | ១.៥% | ១០៦៥ | ៥០០០ | ០៣.០៦.២០២១ |

| | | | | | |
|---|---|---|---|---|---|
| ខែទី៨ | ៦៦.០០០ | ១.៥% | ៩៩០ | ២៥.០០០ | ៣០.០៧.២០២១ |
| ខែទី៩ | ៦៦.០០០ | ១.៥% | ៩៩០ | 0 | |
| ខែទី១០ | ៦៦.០០០ | ១.៥% | ៩៩០ | 0 | ០១.១០.២០២១ |
| សរុប | **៦៦.០០០** | - | **៩៦៣០** | - | - |
| ~~ខែទី១១~~ | ~~៤០.០០០~~ | ~~១.៥%~~ | ~~១០០០~~ | ~~២០.០០០~~ | ~~៣០.១០.២០២១~~ |
| ~~ខែទី១២~~ | ~~២០.០០០~~ | ~~១.៥%~~ | ~~៥០០~~ | ~~០~~ | |
| ~~ខែទី១៣~~ | ~~២០.០០០~~ | ~~១.៥%~~ | ~~៥០០~~ | ~~២០.០០០~~ | ~~៣០.១២.២០២១~~ |

បញ្ជាក់៖

១. ត្រង់ចំនួនប្រាក់ដើមដែលត្រូវសង៖ បន្ទាត់ចូលពីក្រោម គឺជាប្រាក់ដែលបានដែលបានសង។

២. ត្រង់កាលបរិច្ឆេទនៃការសង៖ បន្ទាប់ឆូតពីក្រោមចំនួន ពីរឆូត គឺជាកាលបរិច្ឆេទនៃការសងប្រាក់ដែលបានសងប្រាក់។ បន្ទាត់ឆូតដាច់ៗពីក្រោម គឺជាកាលបរិច្ឆេទដែលដើមចោទបានដាក់ពាក្យបណ្តឹងទាមទារ។

***តុលាការនឹងសម្រេចឱ្យចុងចម្លើយសងការប្រាក់ឱ្យស្របទៅនឹងអត្រាការប្រាក់ដែលបានកម្រិត និងថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ ដល់ថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១ ស្មើនឹងចំនួន ៩៦៣០ (ប្រាំបួនពាន់ប្រាំមួយរយសាមសិប) ដុល្លារអាមេរិក។***

**ឃ. ស្តីពីចំណុចវិវាទទី៣៖** “តើការទាមទារឱ្យសហចុងចម្លើយសងការប្រាក់ពិន័យ ១.៥ (មួយក្បៀសប្រាំ) ភាគរយ នៃប្រាក់ដើមស្របតាមតារាងកាលវិភាគបង់ប្រាក់ដោយគិតចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ រហូតដល់កាលបរិច្ឆេទដែលសហចុងចម្លើយទូទាត់ប្រាក់ដើម និងការប្រាក់គ្រប់ចំនួន ត្រឹមត្រូវដែរទេ?”

**ឃ.១. ការទទួលស្គាល់អង្គហេតុ**

ដើមចោទអះអាងថា បានបង្កើតការសងប្រាក់ពិន័យចំនួន ១.៥ (មួយក្បៀសប្រាំ) ភាគរយនៃប្រាក់ដើម ប៉ុន្តែត្រូវបានចុងចម្លើយបដិសេធចំពោះការទាមទារ។ តុលាការទទួលស្គាល់នូវអង្គហេតុនៃការបង្កើតប្រាក់ពិន័យចំនួន ១.៥ (មួយក្បៀសប្រាំ) ភាគរយ នៃប្រាក់ដើមដែលត្រូវបង់ តាមកិច្ចសន្យាចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០។

**ឃ.២. ការវិនិច្ឆ័យ**

ការប្រាក់ពិន័យដែលមានក្នុងកិច្ចសន្យាចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ រវាងដើមចោទ និងចុងចម្លើយ គឺជាការប្រាក់នៃការយឺតយ៉ាវតាមមាត្រា ៣៩៩ នៃក្រមរដ្ឋប្បវេណី ដែលអត្រាការប្រាក់នេះ ស្មើនឹង ១.៥ (មួយក្បៀស) ភាគរយ នៃអត្រាការប្រាក់ដែលបានកម្រិតចំនួន ១៨ (ដប់ប្រាំបី) ភាគរយក្នុងមួយឆ្នាំ។ ហេតុនេះ ការប្រាក់នៃការយឺតយ៉ាវដែលត្រូវបានបង្កើតឡើងរវាងដើមចោទ និងចុងចម្លើយ គឺត្រឹមត្រូវ។ ម្យ៉ាងវិញ ការប្រាក់នៃការយឺតយ៉ាវ គឺជាសំណងនៃការខូចខាតចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ តាមមាត្រា ៣៩៩ នៃក្រមរដ្ឋប្បវេណី ទោះបីជាមិនបានពុំមានការព្រមព្រៀងបង្កើតក៏ដោយ ក៏ដើមចោទអាចធ្វើការទាមទារឱ្យចុងចម្លើយសងប្រាក់ កាលណាដើមចោទអាចបញ្ជាក់ថា ចុងចម្លើយមានការយឺតយ៉ាវក្នុងការសង។ តាមភស្តុតាងបង្ហាញថា ចុងចម្លើយពុំដែលសងប្រាក់ដើមតាមការកំណត់ ពុំបានសងការប្រាក់តាមការកំណត់ ដែលការយឺតយ៉ាវនេះ កើតឡើងចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ ដែលចុងចម្លើយត្រូវបង់ការប្រាក់ប្រចាំខែឱ្យ

ទៅដើមចោទ ប៉ុន្តែចុងចម្លើយពុំបានបង់។ ហេតុនេះ តុលាការនឹងសម្រេចឱ្យចុងចម្លើយសងការប្រាក់នៃការយឺតយ៉ាវចំនួន **១.៥ (មួយក្បៀស) ភាគរយ** ក្នុងមួយខែ នៃប្រាក់ចំនួន **៨៥,០០០ (ប្រាំបីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក** គិតចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ រហូតដល់ថ្ងៃសហចុងចម្លើយសងប្រាក់គ្រប់ចំនួន។

**ង. ការទាមទារក្នុងចំណុចទី១ ឃ និង ង៖**

**ង.១. ការទទួលស្គាល់អង្គហេតុ**

ដើមចោទទាមទារឱ្យចុងចម្លើយសងការខូចខាតពេលវេលាចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក និងសេវាកម្មច្បាប់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក។ តុលាការទទួលស្គាល់អង្គហេតុថា ការមិនអនុវត្តកាតព្វកិច្ចធ្វើឱ្យកើតមានឡើងនូវចំណាយដែលបង្កើនឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច តាមមាត្រា ៤០០ នៃក្រមរដ្ឋប្បវេណី។

**ង.២. ការវិនិច្ឆ័យ**

ការទាមទាររបស់ដើមចោទមានភាពត្រឹមត្រូវ ប៉ុន្តែដើមចោទពុំបានបង្ហាញភស្តុតាងជាក់លាក់អំពីទំហំនៃការចំណាយ នាំឱ្យតុលាការនឹងសម្រេចក្នុងភាពជាក់ស្តែងដែលមានភាពសមរម្យ ដោយ ***តុលាការនឹងសម្រេចបង្គាប់ឱ្យចុងចម្លើយរួមគ្នាដោយសាមគ្គីភាពសង ចំណាយដែលបង្កើនឡើងដោយសារការមិនអនុវត្តកាតព្វកិច្ចចំនួន ១២.០០០.០០០ (ដប់ពីរលាន) រៀល ឱ្យទៅដើមចោទ។***

៤. សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នចំពោះចំណុចទី១ នៃផ្នែកសេចក្តីសម្រេច។

**ច. ការទាមទារប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន**

ចុងចម្លើយបានធ្វើការតវ៉ាថា ពុំមានភាពចាំបាច់ក្នុងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ប៉ុន្តែពុំមានភស្តុតាងក្នុងការបញ្ជាក់អំពីភាពពុំចាំបាច់ ប៉ុន្តែតុលាការយល់ឃើញថា ការទាមទាររបស់ដើមចោទក្នុងការអនុវត្តជាបណ្តោះអាសន្នលើប្រាក់ចំនួន ៦៦.០០០ (ប្រាំមួយម៉ឺនប្រាំមួយពាន់) ដុល្លារអាមេរិក មានភាពត្រឹមត្រូវ និងចាំបាច់ ព្រោះថាចុងចម្លើយបានទទួលស្គាល់នូវការទាមទាររួចហើយលើប្រាក់នេះ ហើយចុងចម្លើយពុំបានអនុវត្តឱ្យបានត្រឹមត្រូវតាមកិច្ចសន្យា ដែលជាហេតុធ្វើឱ្យដើមចោទមានការខូចខាតផលប្រយោជន៍។ ហេតុនេះ ដើម្បីធានាអំពីសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់របស់ដើមចោទ ***តុលាការនឹងប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នលើប្រាក់ចំនួន ៦៦.០០០ (ប្រាំមួយម៉ឺនប្រាំមួយពាន់) ដុល្លារអាមេរិក តាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។***

**ឆ. អំពីបន្ទុកនៃការប្រាក់ប្រដាប់ក្តី**

**យល់ឃើញថា** តាមមាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និងការសងវិញនូវប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ) មាត្រា ១៨២ កថាខណ្ឌទី៣ (ចំណុចដែលត្រូវវិនិច្ឆ័យដោយសាលក្រម) នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការនឹងសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្តី នៅសាលាដំបូងឱ្យជាបន្ទុករបស់ចុងចម្លើយ។

**សេចក្តីសម្រេចបញ្ចប់**

១. បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] **ពិសិដ្ឋ** និងឈ្មោះ [redacted] **ម៉េងហួត** សងប្រាក់ចំនួន **៦៦.០០០ (ប្រាំមួយម៉ឺនប្រាំមួយពាន់) ដុល្លារអាមេរិក** ឱ្យដើមចោទឈ្មោះ [redacted] **ឈិត**។

២. បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] ម៉េងហួត៖

ក. សងការប្រាក់ចំនួន **៣,៨២៥ (បីម៉ឺនប្រាំបីពាន់ពីររយម្ភៃប្រាំ) ដុល្លារអាមេរិក** គិតចាប់ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ ដល់ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០។

ខ. សងការប្រាក់ចំនួន **៩,៦៣០ (ប្រាំបួនពាន់ប្រាំមួយរយសាមសិប) ដុល្លារអាមេរិក** គិតចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១។

គ. សងការប្រាក់នៃការយឺតយ៉ាវចំនួន **១.៥ (មួយក្បៀស) ភាគរយ** ក្នុងមួយខែ នៃប្រាក់ចំនួន **៨៥,០០០ (ប្រាំបីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក** គិតចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ រហូតដល់ថ្ងៃសហចុងចម្លើយសងប្រាក់គ្រប់ចំនួន។

៣. បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] **ពិសិដ្ឋ** និងឈ្មោះ [redacted] **ម៉េងហួត** រួមគ្នាដោយសាមគ្គីភាពសងចំណាយដែលបង្កើនឡើងដោយសារការមិនអនុវត្តកាតព្វកិច្ចចំនួន **១២.០០០.០០០ (ដប់ពីរលាន) រៀល** ឱ្យទៅដើមចោទឈ្មោះ [redacted] **ឈិត**។

៤. សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នចំពោះចំណុចទី១ នៃផ្នែកសេចក្តីសម្រេច។

៥. ប្រាក់ប្រដាប់ក្តីនៅជាន់សាលាដំបូង គឺជាបន្ទុករបស់សហចុងចម្លើយ។

ថ្ងៃ អង្គារ ១៥ រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ខេត្តកណ្តាល, ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២

**ចៅក្រម**

**ហត្ថលេខា និងត្រា** [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ អង្គារ ១៥ រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ខេត្តកណ្តាល ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២

**បានឃើញ**

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner